និយ័តករគណនេយ្យនិងសវនកម្ម
Accounting and Auditing Regulator

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី “ភាតព្វកិច្ចគណនេយ្យនិងសវនកម្ម” និង “បទប្បញ្ញត្តិពាក់ព័ន្ធ” សម្រាប់សហគ្រាសខេត្តព្រះសីហនុ

ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ត្រូវនឹងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២




នៅព្រឹកថ្ងៃពុធ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ នៅសណ្ឋាគារសុខាខេត្តព្រះសីហនុ **និយ័តករគណនេយ្យនិងសវនកម្ម** បានសហការជាមួយសភាពាណិជ្ជកម្មសាខាខេត្តព្រះសីហនុ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **“កាតព្វកិច្ចគណនេយ្យនិងសវនកម្ម”** និង **“បទប្បញ្ញត្តិពាក់ព័ន្ធ”** សម្រាប់សហគ្រាស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម ដោយមានការអញ្ជើញចូលរួមពី **ឧកញ៉ា វណ្ណា សុខហេង** ប្រធានសភាពាណិជ្ជកម្មខេត្តព្រះសីហនុ តំណាងសាលាខេត្ត តំណាងមន្ទីរពាក់ព័ន្ធក្នុងខេត្ត, ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យ និងសវនកម្ម ព្រមទាំងតំណាងសហគ្រាសជុំវិញខេត្តព្រះសីហនុសរុបចំនួន២៧៨នាក់។

កម្មវិធីសិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្មដល់ម្ចាស់សហគ្រាសនិងភាគីពាក់ព័ន្ធទាំងអស់ក្នុងខេត្តព្រះសីហនុ។




ជាកិច្ចចាប់ផ្តើម **ឧកញ៉ា** ប្រធានសភាពាណិជ្ជកម្ម បានធ្វើសុន្ទរកថាស្វាគមន៍និងបានបង្ហាញឆន្ទៈក្នុងការសហការជាមួយនិយ័តករនិងជំរុញឱ្យសហគ្រាសជាសមាជិកសភាពាណិជ្ជកម្មសាខាខេត្ត ចូលរួមការអនុវត្តកាតព្វកិច្ច

នានា ដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម។

ក្នុងឱកាសដ៏ប្រពៃនោះ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក និយ័តករគណនេយ្យនិងសវនកម្ម បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅទៅកាន់អង្គសិក្ខាសាលាទាំងមូលព្រមទាំងបានថ្លែងសុន្ទរកថាបើកកម្មវិធីដោយបានលើកឡើងថាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានវិលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាព និងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មបានដើរ តួនាទីយ៉ាងសំខាន់និងជារបៀបវារៈអាទិភាពនៅក្នុងកម្មវិធីកំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ហើយក៏បានក្លាយជាវិស័យមួយដែលមានសារៈសំខាន់ ក្នុងការទ្រទ្រង់វិនិយោគ និងធុរកិច្ចតាមរយៈការកសាងហេដ្ឋារចនា សម្ព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យមួយរឹងមាំនឹងអាចជឿទុកចិត្តបាន។ **ឯកឧត្តមអគ្គនាយក** បានបញ្ជាក់ថា បច្ចុប្បន្នមានច្បាប់និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្មបានដាក់ឱ្យអនុវត្ត រួមមាន÷

*១.ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម*
*២.អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម*
*៣.ប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ឱ្យវងសវនកម្មឯករាជ្យ*
*៤.ប្រកាសស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំង*
*៥. សារាចរណ៍ណែនាំ និងសេចក្តីជូនដំណឹងស្តីពីការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលវងសវនកម្មឯករាជ្យ និងមិនវងសវនកម្ម ចំពោះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មកនិយ័តករគណនេយ្យនិងសនកម្ម តាមប្រព័ន្ធអនឡាញ។*

**ឯកឧត្តមអគ្គនាយក** បានគូសបញ្ជាក់ផងដែរថា អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម បានបង្កើតឱ្យមានកាតព្វកិច្ចចំនួន៣គឺ ១) **ការកាន់បញ្ជីគណនេយ្យ ២) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដា និង ៣) ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យវងសវនកម្មឯករាជ្យស្របតាមលក្ខខណ្ឌតាមច្បាប់កំណត់។**

លើសពីនេះ **ឯកឧត្តមអគ្គនាយក** បានបន្ថែមថា **ការកាន់បញ្ជីគណនេយ្យត្រឹមត្រូវ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាជាធរមាននិងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យវងសវនកម្មឯករាជ្យតាមលក្ខខណ្ឌកំណត់គឺជាកាតព្វកិច្ចរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលកំណត់ដោយច្បាប់ប៉ុន្តែនិយ័តករគណនេយ្យនិងសវនកម្ម គឺចង់ឱ្យសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញបង្វែរកាតព្វកិច្ចទាំងនេះទៅជាវប្បធម៌វិញគឺ "វប្បធម៌កាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ វប្បធម៌រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ និង វប្បធម៌ដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យវងសវនកម្មឯករាជ្យ"។**

**ឯកឧត្តមអគ្គនាយក** បន្ថែមទៀតថាវត្តមាននៃច្បាប់ និងលិខិតបទដ្ឋាន ព្រមទាំងវិធានពាក់ព័ន្ធសម្រាប់គ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មមិនមែនជាការដាក់កំហិត ការកំណត់ព្រំដែនឬឧបករណ៍គៀបសង្កត់របស់រាជរដ្ឋាភិបាលចំពោះការរកទទួលទានរបស់ធុរជន និងវិនិយោគិននោះទេ

តែផ្ទុយទៅវិញច្បាប់ និងលិខិតបទដ្ឋានទាំងអស់នោះបាន ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់វិស័យឯកជន ដូចតទៅ **÷បង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការទទួលបាននូវមូលធន ដែលការធ្វើវិភាជន៍មូលធន ប្រកបដោយប្រសិទ្ធភាពដើម្បី បង្កើតប្រសិទ្ធភាពនៃការគ្រប់គ្រងក្រុមហ៊ុន និងបង្កើនជំនឿ ទុកចិត្តរបស់ម្ចាស់ហ៊ុនលើការគ្រប់គ្រងនិងជួយសម្រួល ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ជួយគាំទ្រ ដល់ការរីកចំរើនសេដ្ឋកិច្ចជាតិ និងបង្កើនបរិយាកាស វិនិយោគកាន់តែប្រសើរឡើងជួយរួមចំណែកជំរុញឱ្យទីផ្សារ មូលបត្រមានភាពរឹងមាំ រួមចំណែកការងារសាធារណជន ហើយផ្តល់ទំនុកចិត្តដល់សាធារណជនទៅលើសហគ្រាស នៅលើក្រដាសមួយចំនួនរួមចំណែកបង្កើតការងារជូន ប្រជាពលរដ្ឋ និងធានាប្រសិទ្ធភាព នៃការប្រមូលចំណូល សារពើពន្ធ។**



វាគ្មិននៃនិយ័តករគណនេយ្យនិងសវនកម្មបានធ្វើ បទបង្ហាញស្តីពីបច្ចុប្បន្នភាពនៃកាតព្វកិច្ចគណនេយ្យនិង សវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានចែកចេញជា ៧ចំនុចធំៗគឺ÷១)-ការកាន់បញ្ជីគណនេយ្យ ២)-ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ ៣)-ការដាក់របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ ៤)-ពិន័យអន្តរការណ៍ ៥)-ករណីមិនរាងចាល ឬយឺតយ៉ាវមិនបង់ប្រាក់ពិន័យ ៦)-បណ្តឹងតវ៉ា និង ៧)-ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ មក និ.គ.ស។ លើសពីនេះទៅទៀត ក៏មានធ្វើបទបង្ហាញ ពាក់ព័ន្ធនឹងបច្ចេកទេសក្នុងការរៀបចំរបាយការណ៍ស្រប តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម។ក្នុងនោះដែរតំណាង វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា បាន ធ្វើបទបង្ហាញអំពីវិជ្ជាជីវៈគណនេយ្យនៅកម្ពុជាផងដែរ។

អង្គសិក្ខាសាលា បានលើកជាសំណួរដើម្បីសាក សួរទៅកាន់វាគ្មិន ដែលពាក់ព័ន្ធនឹងច្បាប់និងបទប្បញ្ញត្តិនឹង គណនេយ្យនិងសវនកម្មជាពិសេសបានសំណូមពរអំពីពេល វេលាក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក និ.គ.ស. ដោយហេតុថាសហគ្រាសនៅក្នុងខេត្តព្រះសីហនុមួយចំនួន ជារោងចក្រនៅមិនទាន់បានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ រួចរាល់នៅឡើយ។



ជាទីបញ្ចប់ **ឯកឧត្តមអគ្គនាយក** បានថ្លែង អំណរគុណ **ឧកញ៉ា វណ្ណ សុខហេង** ប្រធានសភា ពាណិជ្ជកម្មខេត្តព្រះសីហនុ ដែលបានផ្តល់ កិច្ចសហការ រៀបចំសិក្ខាសាលា ព្រមទាំងលោក លោកស្រី ដែលជា ម្ចាស់សហគ្រាសទាំងអស់ បានចំណាយពេលដ៏មានតម្លៃ អញ្ជើញចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់នៅក្នុង បរិការណ៍នៃការពង្រឹងអនុលោមភាពតាមច្បាប់និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម។